# ព្រះរាជក្រឹត្យ

នស/រកត/០២២៤/ ១៥០

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដែលសរសេរជាអក្សរកាត់ថា **គ.ក.ច.** ជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងដើម្បីពង្រឹងនិងលើកកម្ពស់គោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ព្រមទាំងគុណភាពនិងប្រសិទ្ធភាពនៃច្បាប់។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ គ.ក.ច.

**មាត្រា២ .-**

**គ.ក.ច.** មានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលនិងមានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គាំទ្រ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

- ផ្តួចផ្តើមនិងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេចលើផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកែទម្រង់ច្បាប់ ផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- លើកសំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចលើប្រព័ន្ធលើកទឹកចិត្តសម្រាប់គាំទ្រដល់ការអនុវត្តការងារកែទម្រង់ច្បាប់ ប្រកបដោយគុណភាព សង្គតិភាព និងប្រសិទ្ធភាព
- រៀបចំគោលការណ៍ណែនាំដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាព ក្នុងការតាក់តែងនិងផ្តល់យោបល់លើការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សំដៅធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព សង្គតិភាព និងភាពសមស្របតាមការវិវត្តនៃសេដ្ឋកិច្ច សង្គម និងដាក់ចេញសេចក្តីណែនាំនិងវិធានការចាំបាច់នានា សំដៅធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការងារកែទម្រង់ច្បាប់
- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពពាក់ព័ន្ធនឹងការងារកែទម្រង់ច្បាប់
- សម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិនានា ដើម្បីជំរុញនិងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ច្បាប់
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល
- ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមគ្រប់មធ្យោបាយ
- ផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពនិងសមិទ្ធផលនានានៃការកែទម្រង់ច្បាប់
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់ច្បាប់ និងលើកសំណើវិធានការចាំបាច់នានាដើម្បីដោះស្រាយបញ្ហាប្រឈមជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច
- អនុវត្តការកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## **ជំពូកទី៣**
## **សមាសភាពរបស់ គ.ក.ច.**

**មាត្រា៣ .-**

**គ.ក.ច.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | អនុប្រធាន |
| - អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអធិការកិច្ច ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ១រូប | សមាជិក |
| - រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ១រូប | សមាជិក |
| - អគ្គលេខាធិការ **គ.ក.ច.** | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ក.ច.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ក.ច.

**មាត្រា៤ .-**

ប្រធាន **គ.ក.ច.** ដឹកនាំកិច្ចការទូទៅរបស់ **គ.ក.ច.**។ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំការងារប្រចាំថ្ងៃជំនួសបាន។

**មាត្រា៥ .-**

**គ.ក.ច.** ប្រជុំសាមញ្ញរៀងរាល់ត្រីមាស ឬតាមការចាំបាច់។ ក្នុងករណីចាំបាច់ **គ.ក.ច.** អាចប្រជុំជាវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធាន **គ.ក.ច.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ក.ច.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៦ .-**

**គ.ក.ច.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ ដៃគូអភិវឌ្ឍ តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិនិងអន្តរជាតិចូលរួមប្រជុំតាមការចាំបាច់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៧ .-**

**គ.ក.ច.** អាចមានទីប្រឹក្សានិងជំនួយការមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

**មាត្រា៨ .-**

**គ.ក.ច.** អាចបង្កើតគណៈកម្មការនិងក្រុមការងារជំនាញមួយចំនួនសម្រាប់ជួយការងាររបស់ខ្លួន។ ការបង្កើត សមាសភាព និងតួនាទីភារកិច្ចរបស់គណៈកម្មការនិងក្រុមការងារជំនាញនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.ច.**។

**មាត្រា៩ .-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបង្កើតក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីជានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការងារកែទម្រង់ច្បាប់ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រា១០ .-**

**គ.ក.ច.** ត្រូវរៀបចំប្រព័ន្ធលើកទឹកចិត្ត ផ្អែកលើសមិទ្ធកម្មសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការដែលចូលរួមក្នុងការអនុវត្តកម្មវិធីកែទម្រង់ច្បាប់ ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

**មាត្រា១១ .-**

**គ.ក.ច.** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**មាត្រា១២ .-**

**គ.ក.ច.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីគាំទ្រដល់កិច្ចដំណើរការការងាររបស់ខ្លួន។

អគ្គលេខាធិការដ្ឋាន **គ.ក.ច.** ដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរង **គ.ក.ច.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥

## ប្រភពធនធានរបស់ គ.ក.ច.

**មាត្រា១៣ .-**

**គ.ក.ច.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**គ.ក.ច.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននូវប្រភពធនធានដែលបានមកពីដៃគូអភិវឌ្ឍនិងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

ក្រុមការងារកែទម្រង់ច្បាប់របស់ក្រសួង ស្ថាប័ន មានប្រភពធនធានសម្រាប់ដំណើរការការងាររបស់ខ្លួនស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួង ស្ថាប័នសាមីនោះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៤ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ ._**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ៤រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០២៤

នសរកត.០២២៤.១៥០

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**